ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

ភ្នំពេញ . ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៧

**សូមគោរពជូន**

**ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កម្មវត្ថុ** : លទ្ធផលប្រជុំក្រុមការងារពិនិត្យឯកសារពិគ្រោះ " ប្រវត្តិកម្ពុជាប្រជាធិបតេយ្យ "

**យោង** : សេចក្តីសំរេចលេខ ៧៧ សសរ. ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

ខ្ញុំសូមអនុញ្ញាតគោរពជំរាបជូន ឯកឧត្តមមេត្តាជ្រាបថា អនុវត្តតាមស្មារតីនៃលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដូចមានយោងខាងលើ ខ្ញុំបាទ រួមជាមួយសមាជិកក្រុមការងារ ពិនិត្យឯកសារពិគ្រោះ " ប្រវត្តិកម្ពុជាប្រជាធិបតេយ្យ " បានរៀបចំការប្រជុំនៅទីស្តីការក្រសួងអប់រំ យុវជន និងកីឡា នារសៀលថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០០៦ដោយមានការចូលរួម ពីសមាជិកក្រុមការងារ ដើម្បីពិភាក្សាពិគ្រោះយោបល់លើការពិនិត្យឯកសារពិគ្រោះ " ប្រវត្តិកម្ពុជាប្រជាធិបតេយ្យ "។ អង្គប្រជុំបានទទួលស្គាល់ថា ឯកសារនេះមាន លក្ខណៈទូលំទូលាយ និងបង្ហាញពីទិដ្ឋភាពជាច្រើននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទន្ទឹមនឹងនេះ អង្គប្រជុំបានកត់សំគាល់ លើចំណុចមួយចំនួនដូចខាងក្រោម :

១.ការបរិយាយហេតុការណ៍ហួសដែនកំណត់នៃរបបកម្ពុជាប្រជាធិបតេយ្យរវាងឆ្នាំ ១៩៧៥-៧៩ ដូចជា : ប្រវត្តិខ្មែរក្រហមដែលច្របល់គ្នាជាមួយនឹងព្រឹត្តិការណ៍ក្នុងរបបសាធារណរដ្ឋខ្មែរ និងមានការលើកឡើង អំពីកម្ពុជាប្រជាធិបតេយ្យក្រោយឆ្នាំ ១៩៧៩ (ទំព័រ ៧៧-៧៩) ។

២.ការលើកឡើងអំពីប្រវត្តិបក្សដែលមានភាពមិនច្បាស់លាស់ ឬ មិនផ្លូវការ (ជំពូកទី២ ទំព័រ ១៣-២១) ។

៣.ការរៀបរាប់ឈ្មោះបុគ្គលជាច្រើន ដែលភាគច្រើនមិនចាំបាច់ត្រូវសិក្សា ហើយនាំឱ្យប៉ះពាល់ដល់សន្តិសុខផ្ទាល់នៃបុគ្គលទាំងនោះ ។

៤.ការរៀបរាប់ភាគច្រើនមានលក្ខណៈជាការនិទានរឿង ដែលមិនមែនជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ។

៥.ការបង្ហាញតួលេខខុសគ្នាចំពោះព្រឹត្តិការណ៍តែមួយដោយមានយោងច្រើនដូចជាតួលេខប្រជាជនកម្ពុជាដែលត្រូវបានសំលាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ទំព័រ ៥៥-៨០) បង្កការលំបាកក្នុងការសិក្សា ។

ទន្ទឹមនឹងនេះ ក្រសួងអប់រំ យុវជន និងកីឡា ក៏មានកម្មវិធីច្បាស់លាស់ដោយបានបញ្ចូលការសិក្សាអំពីរបបកម្ពុជាប្រជាធិបតេយ្យក្នុងកម្មវិធីសិក្សាមុខវិជ្ជា ប្រវត្តិសាស្ត្រថ្នាក់ទី ៩ និងថ្នាក់ទី ១២ សំរាប់ការអប់រំចំណេះទូទៅ ។ ក្រោយពីបាន ពិចារណាលើចំណុចទាំង៥ខាងលើនេះ អង្គប្រជុំបានសម្រេចថា ឯកសារនេះអាចប្រើបានជាឯកសារមូលដ្ឋានសំរាប់ការតែងនិពន្ធ សៀវភៅសិក្សាមេរៀនប្រវត្តិសាស្ត្រ តែមិនទុកជាសៀវភៅសិក្សាប្រវត្តិសាស្ត្រសំរាប់សិស្សចំណេះទូទៅឡើយ ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមឯកឧត្តម មេត្តាជ្រាបជាព័ត៌មាន និងសូមមេត្តាផ្តល់ អនុសាសន៍តាមការគួរ ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ជ.រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា
រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារ

អ៊ឹម សិទ្ធី